

# ការចិញ្ចឹមជីវិតដោយខ្លួនឯង - យុទ្ធសាស្ត្រផ្តោតអាយស៊ីស៊ី

*ប្រទេសកម្ពុជាត្រូវបានគេស្គាល់ថាជាប្រទេសដែលបញ្ជូនពលកររបស់ខ្លួនទៅធ្វើការនៅក្រៅប្រទេស ហើយចាប់តាំងពីឆ្នាំ២០១៧មក ប្រជាជនកម្ពុជាជាងមួយលាននាក់កំពុងតែរស់នៅក្រៅប្រទេសជាពលករ (UNDESA)[1] ។ ពលករចំណាកស្រុកភាគច្រើនសម្រេចចិត្តទៅធ្វើការនៅក្រៅប្រទេស ដោយសារតែចំនួនការងារស្របច្បាប់ក្នុងប្រទេសកម្ពុជានៅមានកម្រិត ហើយដោយសារតែរំពឹងថានឹងទទួលបានប្រាក់ចំណូលខ្ពស់នៅប្រទេសដទៃទៀត។ រហូតមកដល់បច្ចុប្បន្ននេះ តិចជាងមួយភាគបីនៃចំនួនពលករដែលធ្វើការចំណាកស្រុកទាំងអស់បានធ្វើការចំណាកស្រុកតាមបណ្តាញស្របច្បាប់។ ផ្ទុយទៅវិញ ភាគច្រើនបានធ្វើការចំណាកស្រុកខុសច្បាប់ដោយសារតែតម្លៃសេវារដ្ឋបាលថ្លៃ ដំណើរការឯកសារមានរយៈពេលវែង បូករួមជាមួយនិងឧបសគ្គផ្សេងៗទៀត។ បណ្តាញខុសច្បាប់ទាំងនេះរួមមានដូចជា សេវាកម្មជ្រើសរើសពលករតាមប្រព័ន្ធអ៊ីនធឺណិត តាមរយៈអ្នកដែលស្គាល់ និងតាមរយៈមេខ្យល់ដែលមិនមានអាជ្ញាប័ណ្ណ[2] ។*

កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជាត្រូវបានធ្វើឡើងតាមរយៈការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងលើកកម្ពស់ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។ ទោះបីជាយ៉ាងណាក៏ដោយ បញ្ហានេះនៅតែមានកើតឡើងច្រើន។ មុនពេលចាប់ផ្តើមអនុវត្ត គម្រោងកាត់បន្ថយហានិភ័យនៃការធ្វើចំណាកស្រុកខុសច្បាប់ (ក.ប.ធ.ច.ស.ខ.ច) របស់អាយស៊ីស៊ីនៅខេត្តព្រៃវែង ក្នុងឆ្នាំ២០១៧នោះ ប្រជាជនជាច្រើននៅក្នុងសហគមន៍គោលដៅ ត្រូវបានគេបោកបញ្ឆោតដោយប្រើប្រាស់ការសន្យាក្លែងក្លាយដូចជាសន្យាថានឹងបានប្រាក់ចំណូលខ្ពស់និងមានលក្ខខណ្ឌការងារល្អប្រសើរ។ គួរឱ្យសោកស្តាយណាស់ អ្នកភូមិខ្លះបានសម្រេចចិត្តធ្វើការខុសច្បាប់នៅប្រទេសជិតខាងដោយគ្មានឯកសារត្រឹមត្រូវ និងគ្មានលិខិតអនុញ្ញាតការងារដែលទាំងអស់នេះបានធ្វើឱ្យពួកគាត់ប្រឈមមុខនឹងហានិភ័យខ្ពស់។ ពួកគាត់មិនសូវបានយល់ដឹងច្បាស់អំពីនីតិវិធីក្នុងការធ្វើចំណាកស្រុកស្របច្បាប់ឡើយ ហើយពួកគាត់មិនសូវទទួលបានឬមិនទទួលបានព័ត៌មានទាល់តែសោះអំពីការងារ និងលក្ខខណ្ឌការងារនៅក្នុងប្រទេសជិតខាង។

ចាប់តាំងពី គម្រោង ក.ប.ធ.ច.ស.ខ.ច របស់អាយស៊ីស៊ីបានចាប់ផ្តើមធ្វើការអនុវត្តមក ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពមានការកើនឡើងនៅក្នុងសហគមន៍គោលដៅ។ ការចូលរួមចំណែករបស់ គម្រោង ក.ប.ធ.ច.ស.ខ.ច ទៅក្នុងការកើនឡើងនៃការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពនេះគឺដោយសារតែសកម្មភាពផ្សេងៗដូចជា ការលើកកម្ពស់ការយល់ដឹងនិងទប់ស្កាត់ការជួញដូរកំលាំងពលកម្ម ហានិភ័យនៃការធ្វើចំណាកស្រុកខុសច្បាប់ ការគិតត្រិះរិះពិចារណា និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។ ការចែករំលែកបទពិសោធន៍ពីសំណាកជនរងគ្រោះក៏មានអត្ថប្រយោជន៍ផងដែរក្នុងការបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋ។ ប្រសិទ្ធិភាពក្នុងការទប់ស្កាត់មានការកើតឡើងនៅពេលដែលអ្នកភូមិធ្វើការចែករំលែកចំណេះដឹងថ្មីៗនេះទៅដល់អ្នកដទៃ។ ទោះបីជាមានការកើនឡើងនៃការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពនេះក៏ដោយ ប៉ុន្តែការកើនឡើងនេះក៏ដោយសារតែមានច្បាប់តឹងរឹងថ្មីរបស់ប្រទេសថៃ ស្តីពីការគ្រប់គ្រងពលករបរទេស ដែលអនុម័តនៅឆ្នាំ២០១៨ បានធ្វើឲ្យមានការថយចុះនៃការធ្វើចំណាកស្រុកខុសច្បាប់នេះ។

ឧទាហរណ៍ជាក់ស្តែងមួយរបស់ គម្រោង ក.ប.ធ.ច.ស.ខ.ច គឺផ្តោតសំខាន់ទៅលើបុរសវ័យក្មេងម្នាក់ដូចនៅក្នុងរូបភាពខាងលើ ដែលគាត់បានធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ហើយគាត់រកបានការងារសមរម្យជាកម្មករសំណង់នៅក្នុងប្រទេសថៃ។ គាត់ដឹងថាដើម្បីបានទៅធ្វើការនៅប្រទេសថៃស្របច្បាប់នេះគាត់ត្រូវមាន លិខិតឆ្លងដែន លិខិតអនុញ្ញាតិការងារ ទិដ្ឋាការការងារ និងកិច្ចសន្យាការងារ។ បច្ចុប្បន្ននេះ គាត់អាចរកចំណូលបានប្រហែលជា ១៧,០០០ បាតក្នុងមួយខែ (ស្មើនឹង ជាង ៥០០ ដុល្លារអាមេរិក)។ ជាមួយនឹងប្រាក់ខែរបស់គាត់ គាត់អាចទ្រទ្រង់ជីវភាពឪពុកម្តាយចាស់ជរានិងគ្រួសាររបស់គាត់ផ្ទាល់បាន ក៏ដូចជាសងបំណុលគ្រួសាររបស់គាត់ផងដែរ។ គាត់ក៏បានសន្សំប្រាក់ខែខ្លះទុកនៅក្នុងគណនីសន្សំមួយ ក្នុងគោលបំណងពង្រីកកសិដ្ឋានលក្ខណគ្រួសាររបស់គាត់ និងដើម្បីធ្វើការបើកហាងកែសម្ផស្សឱ្យប្រពន្ធគាត់ដើម្បីបង្កើនជីវភាពគ្រួសារនៅពេលដែលគាត់សម្រេចចិត្តត្រឡប់ មកប្រទេសកម្ពុជាវិញ។ ក្នុងនាមជាជនគំរូមួយរូប គាត់បានជួយធ្វើការផ្តល់ដំបូន្មានទៅដល់មនុស្សផ្សេងទៀតដែលមានបំណងចង់ធ្វើការចំណាកស្រុកដោយស្របច្បាប់ទៅប្រទេសថៃ។ រហូតមកដល់ពេលនេះគាត់បានជួយមនុស្សប្រាំពីរនាក់ឱ្យរកបានការងារសមរម្យដូចគាត់នៅប្រទេសថៃ តាមរយៈបណ្តាញស្របច្បាប់។

នេះគឺជាឧទាហរណ៍មួយជាក់ស្តែងដែលបង្ហាញពីផលប៉ះពាល់វិជ្ជមានដែលកើតចេញមកពី គម្រោង ក.ប.ធ.ច.ស.ខ.ច។ ក្រុមការងាររបស់គម្រោងនឹងបន្តកសាងទំនាក់ទំនងឱ្យកាន់តែជិតស្និទ្ធជាមួយនឹង មេភូមិ ក្រុមប្រឹក្សាឃុំ មន្ទីរសង្គមកិច្ចខេត្ត និងអ្នកមានសិទ្ធិអំណាចផ្សេងៗទៀត ព្រោះវាសំខាន់ណាស់នៅពេលដែលអ្នកពាក់ពាន់ទាំងអស់បន្តប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងទប់ស្កាត់ការធ្វើចំណាកស្រុកខុសច្បាប់។ វាជាបំណងប្រាថ្នារបស់អាយស៊ីស៊ី ដែលចង់ឃើញថាអ្នកដែលទទួលបានការយកចិត្តទុកដាក់តិចតួចនិងប្រជាជនក្រីក្រនឹងអាចស្វែងរកការងារសមរម្យបាននៅក្នុងប្រទេស និងនៅក្រៅប្រទេសតាមរយៈបណ្តាញស្របច្បាប់ និងបណ្តាញដែលមានសុវត្ថិភាព ហើយនិងចងឃើញពួកគាត់មានជីវភាពប្រកបដោយនិរន្តរភាព និងមានក្តីសង្ឃឹម និងក្តីសុបិនទៅកាន់អនាគតរបស់ពួកគាត់។

កាលបរិច្ឆេទ៖ កញ្ញា ២០១៩

[1] United Nations, Department of Economic and Social Affairs (UNDESA) (2017). International Migrant Stock: The 2017 Revision.

[2] TRIANGLE in ASEAN Quarterly Briefing Note: Cambodia (2019)